ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងសម្រេចបញ្ជូនកំហុសវិជ្ជាជីវៈ
# របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ចរបស់ពួកគេរៀងៗខ្លួន

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ នេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចចេញដីកាបញ្ជូនកំហុសវិជ្ជាជីវៈរបស់មេធាវី គង់ សំអុន សហមេធាវីជាតិការពារក្តី ខៀវ សំផន ទៅប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជូនកំហុសវិជ្ជាជីវៈរបស់មេធាវី Arthur Vercken និងមេធាវី Anta Guisse សហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន ទៅប្រធានគណៈមេធាវីទីក្រុងប៉ារីស និងអគ្គរដ្ឋអាជ្ញានៃសាលាឧទ្ធរណ៍ទីក្រុងប៉ារីស។

ដីកាសម្រេចបញ្ជូននេះ បានផ្តល់ព័ត៌មានលម្អិតអំពីកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចាប់ពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ មក។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ក្រុមមេធាវីការពារក្តីបានរំលោភបំពានលើដីកាបង្គាប់របស់តុលាការម្តងហើយម្តងទៀត ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២/០២ ដែលទង្វើនេះ គឺជាការធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីយ៉ាងធ្ងន់ធ្ងរ និងដោយចេតនា។ ផលវិបាកដោយផ្ទាល់ដែលកើតចេញពីការប្រព្រឹត្តកំហុសវិជ្ជាជីវៈនេះ គឺសវនាការចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍ត្រូវបានលុបចោល និងបានបង្កើតឲ្យមានការលំបាកដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ការរំខានដល់ភាគីនានា និងការចំណាយជាច្រើនបន្ថែមទៀតរបស់ អ.វ.ត.ក។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានមូលដ្ឋានអង្គហេតុ ឬអង្គច្បាប់សម្រាប់ធ្វើយុត្តិកម្មចំពោះកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តីឡើយ។ ឯកសារចំនួនពីរ ដែលដាក់ដោយមេធាវីការពារក្តីក្នុងគោលបំណងផ្តល់យុត្តិកម្មលើទង្វើរបស់ខ្លួននោះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា មានភាពច្រំដែល គ្មានប្រយោជន៍ និងគាំទ្រដល់យុទ្ធសាស្ត្រការពារក្តីដែលមិនមានមូលដ្ឋានផ្លូវច្បាប់ មិនស្របគ្នាជាមួយនឹងភារកិច្ចរបស់មេធាវី ហើយជាវិធីមួយដើម្បីធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ជាអនុសាសន៍ដល់

អង្គភាពគាំពារការការពារក្តី គួរបដិសេធរាល់សំណើនានា ពីមេធាវីការពារក្តី ខៀវ សំផន ដែលស្នើសុំផ្តល់ប្រាក់កម្រៃសម្រាប់ការងាររបស់ខ្លួនទាក់ទងនឹងការដាក់ឯកសារទាំងពីរនេះ។

ដីកានេះអាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក
www.eccc.gov.kh/document/court/TC-19-December-2014

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

**លោក ឡាស អូលសិន**
មន្ត្រីច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh